ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN
លេខទី ១១ ត្រីមាសទី២ ឆ្នាំ ២០១៩ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION
Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension



# បទពិសោធន៍ជោគជ័យលើ ការងារដាំបន្លែទៅតាមតម្រូវការទីផ្សារ

របស់កសិករ គង់ សារ៉ន រស់នៅឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

ព្រឹត្តប័ត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រង នូវរាល់បទពិសោធន៍ជោគជ័យ លើការងារ និងមុខរបរផ្សេងៗ ដែលជាស្នាដៃអនុវត្តផ្ទាល់របស់កសិករ ក៏ដូចជាសហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តការងារមកចងក្រង និងធ្វើការផ្សព្វផ្សាយជូនដល់ប្រជាជាកសិករ សហគមន៍ និងដៃគូពាក់ព័ន្ធផ្សេងទៀតដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ការអនុវត្តការងារ និងប្រកបរបរពាក់ព័ន្ធនឹងវិស័យកសិកម្ម។

ព្រឹត្តិប័ត្រព័ត៌មានកសិកម្មនេះដែរ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បានលើកយកបទពិសោធន៍ជោគជ័យ របស់កសិករឈ្មោះ **គង់ សារ៉ន** រស់នៅភូមិកំពង់ត្រឡាចលើ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាកសិករឆ្នើម ធ្លាប់ទទួលបានទទួលជ័យលាភី លើការងារដាំបន្លែទៅតាមតម្រូវការទីផ្សារមកបង្ហាញជូនដូចខាងក្រោម៖

## ១- អំពីប្រវត្តិ

លោក **គង់ សារ៉ន** និងគ្រួសារ មានទីលំនៅបច្ចុប្បន្នក្នុងភូមិកំពង់ត្រឡាចលើ ឃុំត្បូងកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ពាក់ព័ន្ធនឹងការងារធ្វើកសិកម្មគាត់បានរៀបរាប់ប្រាប់ថា ពេលចាប់ផ្តើមធ្វើការងារដាំបន្លែជាលើកដំបូង គឺគាត់បានធ្វើទៅតាមទម្លាប់តៗគ្នាពីដូនតាតរបស់គាត់ដែលពេលនោះគាត់ទទួលបានទិន្នផលតិចតួច ធ្វើឱ្យការរស់នៅរបស់ក្រុមគ្រួសារគាត់មានជីវភាពខ្វះមុខខ្វះក្រោយ ដោយសារមិនមានបច្ចេកទេសក្នុងការអនុវត្តលើមុខរបរនេះ ក្រោយទទួលបានការបណ្តុះបណ្តាល ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង ក៏ដូចជាអង្គការ និងគម្រោងកម្ម



ស្រះចិញ្ចឹមត្រីនៅពីមុខផ្ទះកសិករ គង់ សារ៉ន

វិធីមួយចំនួនទៀតដែលធ្វើការពាក់ព័ន្ធនឹងការងារកសិកម្មនេះមក ការងារដាំបន្លែរបស់គាត់ទទួលបានទិន្នផលខ្ពស់ជាក់ស្តែង ការដាំដុះដំបូង ក្រោយទទួលបានការបណ្តុះបណ្តាល លើផ្ទៃ៥អា គាត់ទទួលទិន្នផលត្រសក់ចំណាររចំនួន



ដំណាំត្រសក់ដាំតាមលក្ខណៈបច្ចេកទេស

២តោន ធ្វើឱ្យរូបគាត់ និងគ្រួសារមានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើការងារនេះ ។ រហូតមកពេលបច្ចុប្បន្ន គាត់បានធ្វើការពង្រីកផ្ទៃដីដាំដុះ ស្ទើរតែពេញដីដែលគ្រួសារមានអស់ទៅហើយ។



គ្រួសារកសិករ គង់ សាវ៉ន កំពុងទទួលការណែនាំបច្ចេកទេសពីមន្ត្រីជំនាញកសិកម្ម

កសិករ គង់ សាវ៉ន បានរៀបរាប់បន្តទៀតថាកាលពីពេលមុន ក្នុង១ថ្ងៃ គ្រួសាររបស់គាត់រកប្រាក់ចំណូលបានត្រឹមតែ៥០០រៀល តែប៉ុណ្ណោះ តែឥឡូវគ្រួសារគាត់មានលទ្ធភាពរកប្រាក់ចំណូលបានពី ៣០០.០០០-៤០០.០០០ រៀលក្នុងមួយថ្ងៃ ធ្វើឱ្យជីវភាពគ្រួសាររបស់គាត់មានការប្រែប្រួលច្រើន ដោយគាត់មានលទ្ធភាពបញ្ជូនកូនទៅសាលារៀន សាងសង់គេហដ្ឋាន ទិញឧបករណ៍សម្រាប់ធ្វើកសិកម្ម ពង្រីកមុខរបរកសិកម្មដូចជា ជីកស្រះចិញ្ចឹមត្រី ជាដើម ។



របងចូលផ្ទះកសិករ គង់ សាវ៉ន ក្រោយទទួលបានជោគជ័យលើការងារដាំដំណាំបន្លែ

កសិករ គង់ សាវ៉ន បានរៀបរាប់បន្ថែមទៀតថាមុខរបរធ្វើកសិកម្មធ្វើឱ្យគ្រួសារគាត់ អាចមានប្រាក់ចំណូលជារៀងរាល់ថ្ងៃ និងធ្វើឱ្យគ្រួសារគាត់អាចរស់នៅជួបជុំគ្នាដោយមិនចាំបាច់ធ្វើចំណាកស្រុក។



គ្រួសារកសិករ គង់ សាវ៉ន កំពុងផ្តល់ចំណីឱ្យត្រីនៃលចិញ្ចឹកក្នុងស្រះនៅខាងមុខផ្ទះ

## ២- អំពីដំណើរការនៃការធ្វើកសិកម្ម

កសិករ គង់ សាវ៉ន បានរៀបរាប់ឱ្យដឹងដែរថាដោយសារការយកចិត្តទុកដាក់ពីមន្ត្រីជំនាញ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង ដែលតែងតែចុះមកណែនាំនិងបង្ហាត់បង្រៀននូវបច្ចេកទេសថ្មីៗ បានធ្វើឱ្យគាត់មានការចាប់អារម្មណ៍ និងបានពង្រីកផ្ទៃដីដាំដុះជាបន្តបន្ទាប់។ កសិករ គង់ សាវ៉ន បានបន្តទៀតថា ក្នុងចម្ការរបស់គាត់មានដាំដំណាំត្រសក់ ម្រះ ម្ទេស ត្រប់ សណ្តែកកួរ ននោង និងបន្លែយកស្លឹក មានដូចជាដំណាំផ្ទី ឬស្លឹកម្រះជាដើម។



ការពង្រីកផ្ទៃដីដាំដុះដំណាំបន្លែរបស់កសិករ គង់ សាវ៉ន ដើម្បីបំពេញតម្រូវការទីផ្សារ

គាត់បានឱ្យដឹងទៀតថា ការដាំដុះដំណាំបន្លែរបស់គាត់គឺដាំទៅតាមតម្រូវការទីផ្សារ ទើបទទួលបានតម្លៃខ្ពស់។ ចំពោះអាយុកាលដំណាំវិញ គាត់ក៏បានឱ្យដឹងដែរថា ដំណាំម្រះអាយុត្រឹមតែ ៦០ ថ្ងៃអាចប្រមូលផលបាន ហើយចាប់ពីប្រមូលផលលើកទីមួយហើយ គឺគាត់អាចប្រមូលផលបានជារៀងរាល់ថ្ងៃរហូតដល់១ខែកន្លះ ទៅ២ខែ អាស្រ័យតាមការថែទាំ ដោយក្នុង១ថ្ងៃចំពោះដំណាំម្រះគាត់អាចប្រមូលផល



ការប្រមូលផលដំណាំម្រះរបស់កសិករ គង់ សាវ៉ន
និងគ្រួសាររបស់គាត់

បានចន្លោះពី២០ ទៅ ៣០ គីឡូក្រាម អាស្រ័យទៅតាមការបញ្ជាទិញពីអតិថិជនរបស់គាត់។ ចំពោះដំណាំត្រសក់ក្រោយការដាំដុះមានអាយុ៣០ ទៅ ៣២ ថ្ងៃ យ៉ាងយូរយើងអាចប្រមូលផលបាន ហើយដោយសារគាត់បានជ្រើសរើសពូជដែលមានអាយុកាលខ្លី កសិករ **គង់ សាវ៉ន** ក៏បានឱ្យដឹងដែរថាដំណាំត្រសក់ក៏ដូចជាដំណាំម្រះដែរ បើបានប្រមូលផលហើយគឺគាត់អាចប្រមូលផលបានជារៀងរាល់ថ្ងៃ ដោយមិនទុកឱ្យផ្លែចាស់ពេកពិបាកក្នុងការលក់រយៈពេលនៃការប្រមូលបានរហូតទៅ១ខែឬច្រើនជានេះក៏មាន។



ផលិតផលដំណាំត្រសក់របស់កសិករ គង់ សាវ៉ន



ផលិតផលដំណាំម្រះរបស់កសិករ គង់ សាវ៉ន

រីឯដំណាំសណ្តែកកួរ ក្រោយការដាំដុះវាមានរយៈពេល៦០ថ្ងៃដែរទើបអាចធ្វើការប្រមូលផលបាន ហើយអាចប្រមូលបានជារៀងរាល់ថ្ងៃដូចទៅនឹងប្រភេទដំណាំបន្លែផ្សេងៗទៀតដែរ ប៉ុន្តែសណ្តែកកួរ អាចធ្វើការប្រមូលផលបានយូររហូតដល់រយៈពេល២ខែ ដោយសារដំណាំនេះធន់ទ្រាំទៅនឹងការខ្វះទឹក។

កសិករ **គង់ សាវ៉ន** បានបញ្ជាក់ប្រាប់ថាការដាំដុះជាសំខាន់ត្រូវមានផែនការ ដោយត្រូវធ្វើយ៉ាងណាផ្គត់ផ្គង់ដល់ទីផ្សារ ឱ្យមានបន្លែលក់ជារៀងរាល់ថ្ងៃ ដូច្នេះការប្រមូលផលបន្លែរបស់គាត់ ក៏ត្រូវឱ្យមានលក្ខណៈវិលជុំ អស់ពីចម្ការមួយចូលដល់ចម្ការមួយទៀត។







ចំពោះទីផ្សារកសិករ **គង់ សាវ៉ន** បានបញ្ជាក់ប្រាប់ថា គាត់បានលក់ឱ្យអតិថិជន ដែលបានមកយកបន្លែរបស់គាត់ដល់ចម្ការតែម្តង  ដោយគាត់បានធានាដល់ម៉ូយរបស់គាត់ បើក្នុងករណីលក់បន្លែមិនអស់អាចយកមកឱ្យគាត់វិញ។



*គ្រួសារកសិករ គង់ សាវ៉ន រៀបចំបន្លែ ឱ្យអតិថិជនរបស់គាត់*

ជាចុងក្រោយ ពេលដែលក្រុមការងារឃើញកសិករ **គង់ សាវ៉ន** ដាំដំណាំសុទ្ធតែមានគ្របប្លាស្ទិក ក៏បានសួរគាត់ថា ការដាំដំណាំមានគ្របប្លាស្ទីក និងមានប្រព័ន្ធដំណក់ទឹកអញ្ចឹងតើវាមានប្រយោជន៍អ្វីខ្លះដល់ដំណាំ? គាត់តបវិញថា មានប្រយោជន៍ច្រើនដូចជាទី១ ចំណេញពេលវេលាដោយយើងមិនចាំចាច់ដើរស្រោច សម្រាប់ទុយោទឹកគឺយើងបើកតែក្បាលរ៉ូមីណេទៅបានហើយ ។ ចំពោះការគ្របកៅស៊ូប្លាស្ទីកវិញក៏វាជួយធ្វើឱ្យដីមិនហាប់ ធ្វើឱ្យដំណាំអាចដុះលូតលាស់បានល្អ  ដោយសាមិនមានស្មៅចង្រៃដណ្តើមជីជាតិ រក្សាសំណើមដីបានយូរបន្ទាប់ពីបានធ្វើការស្រោចស្រព។



*ការរៀបចំប្រព័ន្ធដំណក់ទឹកមុនគ្របប្លាស្ទិក សម្រាប់ដាំដំណាំបន្លែ*



*ការដាំដំណាំដោយគ្របប្លាស្ទិកជួយឱ្យរក្សាសំណើមដីបានយូរ ស្មៅមិនអាចដុះដែនដាមួយដំណាំ*

ចំពោះទិសដៅបន្ត កសិករ **គង់ សាវ៉ន** បានឱ្យដឹងថា គាត់មានគម្រោងពង្រីកការដាំដុះដំណាំឱ្យបានច្រើនជាមុន ដោយសារបច្ចុប្បន្នមានតម្រូវការច្រើននៅក្នុងទីផ្សារ  ជាក់ស្តែង ក្នុងពេលបច្ចុប្បន្នទីផ្សារមានតម្រូវការច្រើន តែយើងគ្មានបន្លែឱ្យគេ  ដូចជាសពថ្ងៃនេះក្នុង១ព្រឹកគាត់មានបន្លែឱ្យគេតែ ៥ ទៅ៦ មុខប៉ុណ្ណោះ តែអ្នកលក់ត្រូវការដាក់លក់បន្លែនៅលើតូបរបស់គាត់ពី១០មុខ ឬច្រើនជាងនេះ។



*ប្រភេទបន្លែដែលកំពុងមានតម្រូវការនៅក្នុងទីផ្សារនាពេលបច្ចុប្បន្ន*

ជាសំណូមពររបស់កសិករ **គង់ សាវ៉ន** គាត់ចងឱ្យកសិករជិតខាង  និងក្រៅតំបន់របស់គាត់  ក្លាយជាកសិករផលិតដូចគាត់ ដើម្បីជួយឱ្យជីវភាពគ្រួសារមានភាពរីកចម្រើន មិនចាំបាច់ធ្វើចំណាកស្រុក គ្រួសារអាចរស់នៅជួបជុំគ្នា យ៉ាងសុខដុមរម្យនា។

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង
- កសិករ គង់ សាវ៉ន រស់នៅភូមិកំពង់ត្រឡាចលើ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០៧១ ២២១ ១៩០